# ភាពសុខដុមរមនាខាងជាតិសាសន៍ និង សាសនា

ការរស់នៅជាសហគមន៍ទាំងចិន ទាំងវៀតណាម ចាម និង ខ្មែរបាន ប្រព្រឹត្តទៅដោយសុខដុមរមនារវាងគ្នា និង គ្នាល្អណាស់ ។ ចិនៗ ទោះបីនៅជាអាណិជកជនបរទេសក៏ដោយ ក៏ត្រូវបានអ្នកស្រុកអ្នកភូមិ រាប់អានស្មើភាពគ្នា ដោយគ្មានប្រកាន់ជាតិសាសន៍អ្វីឡើយ ។

ក្រៅពីជនជាតិវៀតណាមកាត់ចិនពីរគ្រួសារ ដែលប្រកបរបរដើរឡានឈ្នួល មាន គ្រួសារពីរទៀតដែលរស់នៅក្នុងភូមិស្នាយពល ។ គ្រួសារមួយជាជាងកាត់ដេរខោអាវ និង មួយទៀតរកស៊ីចិញ្ចឹមជ្រូក ដាំបន្លែ និង លក់ម្ហូបអាហារវៀតណាម ជាពិសេស លក់បាញ់ហយ ។ អ្នកស្រុកភូមិយើងចាត់ទុកជនជាតិវៀតណាមជាអាណិកជនបរទេសខ្លាំងជាងពួកចិន ព្រោះពួកនេះមិនកាន់ព្រះពុទ្ធសាសនា និង មិនដែលទៅវត្តជាមួយពួកខ្មែរយើងម្តងណាឡើយ ។ ក្រៅពី ចិន និង វៀតណាម នៅមានជនជាតិចាមមួយគ្រួសារទៀតដែរ តែប្រហែលជាដោយសារពុំមានវិហារចាម បានជាគេមិនសូវឃើញពួកនេះនៅក្នុងភូមិ ។ យូរៗទៅគេក៏មិនឃើញមានជនជាតិចាមរស់នៅតទៅទៀតឡើយ ។ ដូច្នេះនៅទីបំផុត មុខរបរកាប់គោលក់សាច់ ក៏ត្រូវបានធ្លាក់មកជនជាតិខ្មែរវិញ ។ តាមធម្មតា ពួកចាមនាំគ្នាប្រកបរបរនេសាទត្រី ឬ កាប់គោយកសាច់លក់ ។ នៅភូមិស្នាយពល គេហាក់ដូចជាធ្វើការបែងចែកភារកិច្ចគ្នារវាងជនជាតិ ចិន ចាម និង វៀតណាម ក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ ចិនៗលក់សាច់ជ្រូក ពួកចាមលក់សាច់គោ ។ សាសនារបស់ពួកចាមមិនអនុញ្ញាតឲ្យទទួលទានសាច់ជ្រូកទេ ។ ពួកចាមកាន់សាសនាឥស្លាម បានត្រូវចាត់ទុកជាជនជាតិខ្មែរពេញសិទ្ធិ ដែលគេហៅថា "ខ្មែរឥស្លាម" ។ តាមសៀវភៅប្រវត្តិសាស្ត្រដែលខ្ញុំបានអាន ជនជាតិចាមមានកំណើត នៅក្នុងប្រទេសមួយឈ្មោះ "ចម្ប៉ា" ដែល

បានត្រូវវៀតណាម វាយយកទឹកដី បំបាត់ចេញពីផែនទីពិភពលោកច្រើនរយឆ្នាំមកហើយ ។ ទីតាំងប្រទេសចម្ប៉ា ស្ថិតនៅចំតំបន់អណ្ណាមកណ្តាលនៃប្រទេសវៀតណាមបច្ចុប្បន្ន ។ ព្រះចៅនៃប្រទេសចម្ប៉ាចុងក្រោយបង្អស់ និង សេនាវរេហ៍ពលរបស់ព្រះអង្គត្រូវបានភៀសខ្លួនមករស់នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ១៧២០[10] ។ នៅក្នុងភូមិស្នាយពលកាលសម័យមុនសង្គ្រាម ជនជាតិខ្មែរ ចិន វៀតណាម និង ចាម ឬ ខ្មែរឥស្លាម បានរស់នៅជាមួយគ្នាដោយសុខសាន្តពុំមានទំនាស់រវាងគ្នា និងគ្នាទេ ។

[10] D G E Hall, A History of South-East Asia, Third Edition, London, 1968, p. 194.